## ២-សេចក្ដីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩៩

**សេចក្ដីសំរេចលេខ ៥៥ សសរ**

**ស្ដីពីការចាត់តាំងមន្ត្រីត្រួតពិនិត្យការអនុវត្តន៍**

**កិច្ចសន្យារវាងក្រសួងមហាផ្ទៃ និងក្រុមហ៊ុនវ៉ូយ៉ាល់គ្រួប**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើត ទីស្ដីការក្រសួងមហាផ្ទៃ
- បានឃើញកិច្ចសន្យារវាងក្រសួងមហាផ្ទៃ និងក្រុមហ៊ុនវ៉ូយ៉ាល់គ្រួប ស្ដីពីគំរោងការតភ្ជាប់ ប្រព័ន្ធកុំព្យូទ័រ Computer Integrated System and Information រវាងក្រសួងមហាផ្ទៃទៅនឹងព្រលានយន្តហោះ និងគ្រប់ខេត្ត-ក្រុងនានាទូទាំងប្រទេស
- យោងតាមការចាំបាច់របស់ រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១ :** ប្រគល់ភារកិច្ចជូនឯកឧត្តម ប៉ាន់ សូរស័ក្តិ បច្ចុប្បន្នជាអនុរដ្ឋលេខាធិការ ទីស្ដីការគណៈរដ្ឋមន្ត្រីអោយទទួលបន្ទុកទំនាក់ទំនងតាមដាន ណែនាំ ផ្ដល់យោបល់ និង ត្រួតពិនិត្យគ្រប់កិច្ចការបច្ចេកទេសក្នុងការកសាងប្រព័ន្ធ កុំព្យូទ័រ Computer Integrated System and Infomation ជាមួយក្រុមហ៊ុនវ៉ូយ៉ាល់គ្រួប ។

**ប្រការ ២ :** ឯកឧត្តម ប៉ាន់ សូរស័ក្តិ ត្រូវរាយការណ៍លទ្ធផលការងារជូន សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃតាមជំហាននិមួយៗ ។ ក្នុងករណីពិនិត្យឃើញមានចំណុចណាមិនសមស្របតាមខ្លឹមសារនៃកិច្ចសន្យាត្រូវណែនាំអោយកែសំរួលឡើងវិញ ។

ប្រការ ៣ : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល និងសាមីខ្លួន ដែលមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្ត សេចក្តីសំរេច ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ១៩៩៩

ឧបនាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស ខេង

★★★

# III- ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩៩

### ប្រកាសលេខ ៥១៨ ឧក.ប្រក

### រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេច នរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ ១៣៥/៩៨ក.អ.ក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ០៤៧ប.ស្ត.ស.ជ.ណ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៩ របស់ក្រសួងបរិស្ថាន
- បានឃើញលិខិតលេខ ៣៨៦ ធត.ស ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់សាលាក្រុងភ្នំពេញស្តីពីការអនុញ្ញាតអោយបើកទីតាំងសាខារោងចក្រកាត់ដេរសំលៀកបំពាក់
- យោងពាក្យស្នើរបស់ក្រុមហ៊ុន សាន សាន ហ្គារម៉េន ខាំបូឌៀ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៩